**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៥៦២ សជណ

**សូមគោរពជូន**
**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា**

**កម្មវត្ថុ** : ករណីការស្នើរបស់ក្រុមអ្នកតំណាងរាស្ត្រគណបក្ស **សម រង្ស៊ី** ចំនួន០៤រូបគឺ : ឯកឧត្តម **សម រង្ស៊ី**, ឯកឧត្តម **យឹម ឡាក់គី**, ឯកឧត្តមមៅ **មុនីវណ្ណ** និងឯកឧត្តម **ជាម ច័ន្ទនី** សុំឲ្យរាជរដ្ឋាភិបាលឆ្លើយនូវសំណួរដែលបានចោទប្រកាន់រាជរដ្ឋាភិបាលរំលោភលើកិច្ចព្រមព្រៀង ទីក្រុងប៉ារីសឆ្នាំ១៩៩១ ស្តីពីកម្ពុជា ។

**យោង** : លិខិតលេខ ៦៦១ រ.ស ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ ២០១០ របស់រដ្ឋសភា ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ សូមជម្រាបជូន**សម្តេចអគ្គមហាពញាចក្រី** ប្រធានរដ្ឋសភា មេត្តាជ្រាបថា ជាដំបូងបង្អស់មុននឹងខ្ញុំបំពេញកាតព្វកិច្ចឆ្លើយបំភ្លឺជូនម្ចាស់សំណួរ គឺខ្ញុំត្រូវពិនិត្យយ៉ាងម៉ត់ចត់លើខ្លឹមសារ និងចរិតលក្ខណៈនៃលិខិតនេះ។ លើសពីនេះទៅទៀត ក្នុងតួនាទីខ្ញុំជានាយករដ្ឋមន្ត្រី ដែលជាប្រមុខដឹកនាំអំណាចនីតិប្រតិបត្តិនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំគោរពទទួលស្គាល់នីត្យានុកូលភាពប្រជាធិបតេយ្យ និងសិទ្ធិអំណាចរបស់រដ្ឋសភា ក្នុងឋានៈជា សភាតំណាងរាស្ត្ររបស់ប្រជាពលរដ្ឋខ្មែរ និងជាស្ថាប័ននៃអំណាចនីតិប្បញ្ញត្តិកំពូលរបស់ជាតិផ្អែកលើ គោលការណ៍បែងចែកអំណាច តាមប្រព័ន្ធគ្រប់គ្រងរដ្ឋបែបប្រជាធិបតេយ្យសភានិយម ដែលបានបញ្ញត្តិ ក្នុងរដ្ឋធម្មនុញ្ញ ជាពិសេសសិទ្ធិអ្នកតំណាងរាស្ត្រ ក្នុងការដាក់សំណួរមករាជរដ្ឋាភិបាល ដូចមានចែងក្នុង មាត្រា៩៦ នៃរដ្ឋធម្មនុញ្ញ។

ប៉ុន្តែដោយឡែកចំពោះលិខិតរបស់អ្នកតំណាងរាស្ត្រ០៤ រូប ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១០ នេះ គឺមានកម្មវត្ថុ**ចោទប្រកាន់**រាជរដ្ឋាភិបាលថា "...**រំលោភ**លើកិច្ចព្រមព្រៀងទីក្រុងប៉ារីស..." យ៉ាងច្បាស់លាស់រួចស្រេចទៅហើយ។ មិនតែប៉ុណ្ណោះ លិខិតនេះបានផ្តើមចេញពី**ការចោទប្រកាន់**រាជរដ្ឋាភិបាល ដោយចោទសំណួរជាដំបូងបង្អស់ថា " មូលហេតុអ្វីបានជារាជរដ្ឋាភិបាល **រំលោភ**លើកិច្ចព្រមព្រៀងទីក្រុងប៉ារីស ..." មុននឹងតាំងសំណួរបីផ្សេងទៀត។ ចរិតលក្ខណៈចោទប្រកាន់បែបនេះ សរបញ្ជាក់ឲ្យឃើញ ថាម្ចាស់លិខិតបានសម្តែងជំហរយល់ឃើញច្បាស់លាស់របស់ខ្លួនរួចស្រេចបាច់ទៅហើយ ពោលគឺម្ចាស់សំណួរ ពុំមានភាពមន្ទិលអ្វីដែលតម្រូវឲ្យខ្ញុំឆ្លើយបំភ្លឺនោះទេ។ អាស្រ័យហេតុនេះ បើម្ចាស់សំណួរបានធ្វើការចោទប្រកាន់រាជរដ្ឋាភិបាលថា "...រំលោភលើកិច្ចព្រមព្រៀងទីក្រុងប៉ារីស..." អញ្ចឹងទៅហើយនោះ គួរតែម្ចាស់សំណួរ ប្រើសិទ្ធិស្របច្បាប់របស់ខ្លួន ប្តឹងទៅអំណាចតុលាការឲ្យធ្វើការវិនិច្ឆ័យវិញទើបត្រឹមត្រូវតាមរដ្ឋធម្មនុញ្ញ ព្រោះវេទិការដ្ឋសភា ពុំមែនជាសវនាការវិនិច្ឆ័យលើការចោទប្រកាន់របស់អ្នកតំណាងរាស្ត្រមកលើរាជរដ្ឋាភិបាលទេ ហើយនាយករដ្ឋមន្ត្រីក៏ដូចជាសមាជិករាជរដ្ឋាភិបាលដទៃទៀត ក៏ពុំគួរយកវេទិការដ្ឋសភា សម្រាប់ប្រើសិទ្ធិ និងបំពេញកាតព្វកិច្ចឆ្លើយបំភ្លឺដើម្បីដោះបន្ទុកចំពោះការចោទប្រកាន់របស់អ្នកតំណាងរាស្ត្រនោះផងដែរ។

ដូច្នេះក្នុងនាមខ្ញុំជានាយករដ្ឋមន្ត្រី និងក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំពុំមានសិទ្ធិអំណាចធ្វើផ្ទុយនឹងរដ្ឋធម្មនុញ្ញ ឬក៏រំលោភលើគោលការណ៍បែងចែកអំណាច, គោលការណ៍នីតិរដ្ឋ និងរបៀបរបបគ្រប់គ្រង

រដ្ឋបែបប្រជាធិបតេយ្យសភានិយម ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញបានទេ។ ឈរលើមូលដ្ឋានរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំគួរតែប្រុងប្រយ័ត្ន មិនចូលរួមបង្កើតឲ្យមានទម្លាប់ខុសឆ្គងណាមួយ ដោយប្រើប្រាស់វេទិការដ្ឋសភាធ្វើជាសវនាការសម្រាប់ចោទប្រកាន់ និងឆ្លើយដោះបន្ទុក ព្រោះវិធានបែបនេះមិនស្ថិតក្នុងរបៀបរបបគ្រប់គ្រងរដ្ឋបែបប្រជាធិបតេយ្យសភានិយមទេ។ ប៉ុន្តែក្នុងនាមខ្ញុំជាប្រមុខដឹកនាំរាជរដ្ឋាភិបាលទទួលខុសត្រូវចំពោះរដ្ឋសភាអនុលោមតាមរដ្ឋធម្មនុញ្ញ ទាំងខ្ញុំ និងទាំងសមាជិកគណៈរដ្ឋមន្ត្រីរបស់ខ្ញុំ សូមស្វាគមន៍ឆ្លើយបំភ្លឺជានិច្ច ជូនអង្គសភា ចំពោះរាល់ការតាំងសំណួរទាំងឡាយណារបស់អ្នកតំណាងរាស្ត្រដែលពុំយកការចោទប្រកាន់ជាអាទិភាព។

ម្យ៉ាងទៀតរបៀបនៃការសរសេរលិខិតនេះ គឺគ្មានលក្ខណៈជាការឆ្លើយឆ្លងរវាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិក្នុងគោលដៅដើម្បីកសាងជាតិឬ ធ្វើឲ្យមានការវិវត្តន៍ជាវិជ្ជមាននោះឡើយ តែនេះគ្រាន់តែជាឥរិយាបទដែលឆ្លុះបញ្ចាំងឲ្យឃើញនូវអ្វីដែលជាការញុះញង់បង្ករឿងតែប៉ុណ្ណោះ ដែលការញុះញង់បង្ករឿងគឺជាល្បិចរបស់អ្នកប្រឆាំងដែលអនុវត្តទៅគ្រាន់តែជាការបំផ្លិចបំផ្លាញតែប៉ុណ្ណោះ។

អ្នកនយោបាយដែលនិយមការញុះញង់បង្ករឿងមិនមែនជាអ្នកនយោបាលដែលមានផលប្រយោជន៍ចំពោះជាតិនោះទេ ហើយក៏ពុំឆ្លើយតបទៅនឹងគោលការសំខាន់នៃលទ្ធិប្រជាធិបតេយ្យឡើយ។

លើសពីនេះទៅទៀតអ្វីដែលគួរឲ្យខ្មាសអៀនជាងនេះ នៅក្នុងឋានៈជាជនជាតិកម្ពុជា ខ្ញុំមានការសោកស្តាយយ៉ាងខ្លាំងចំពោះការចោទប្រកាន់របស់អ្នកតំណាងរាស្ត្រទាំង០៨រូប ដែលជាជនជាតិកម្ពុជាគឺដូចគ្នាទាំងស្រុងទៅនឹងការចោទប្រកាន់ជារឿយៗរបស់ក្រុមនិយមជ្រុលថៃមកលើកម្ពុជា ហើយដែលរាជរដ្ឋាភិបាលកម្ពុជាធ្លាប់បានឆ្លើយបំភ្លឺរួចមកហើយ។ ការចោទប្រកាន់នេះបង្ហាញយ៉ាងច្បាស់ថា តំណាងរាស្ត្រគណបក្សសម រង្ស៊ី បាននឹងកំពុងការពារ បម្រើដល់ប្រយោជន៍ប្រទេសដទៃប្រឆាំងនឹងជាតិខ្លួនឯងក្នុងខណៈពេលប្រទេសជិតខាងកំពុងតែឈ្លានពានទឹកដីកម្ពុជា ដែលផ្ទុយទៅនឹងការសច្ចាប្រណិធានរបស់អ្នកតំណាងរាស្ត្រខ្មែរដែលបានចែងថា៖ «ទូលព្រះបង្គំយើងខ្ញុំ សូមប្តេជ្ញា ប្តូរផ្តាច់ហ៊ានបូជាជីវិត ដើម្បីការពារជានិច្ចទាំងក្នុងបច្ចុប្បន្ន ទាំងក្នុងអនាគត នូវ :

- ឯករាជ្យភាពទាំងស្រុងនៃមាតុភូមិកម្ពុជា
- អធិបតេយ្យភាពជាតិពេញបរិបូណ៌
- បូរណភាពទឹកដីដ៏ត្រឹមត្រូវតាមច្បាប់
- ឯកភាពជាតិ ហើយមិនអនុញ្ញាតឲ្យមានការបែងចែក ឬការធ្វើអបគមន៍ណាមួយឡើយ។

ទូលព្រះបង្គំយើងខ្ញុំ.......មិនអនុញ្ញាតជាដាច់ខាតឲ្យជនណាក៏ដោយដែលចង់ជ្រៀតជ្រែកចូលក្នុងកិច្ចការផ្ទៃក្នុងនៃកម្ពុជា ឬមកបង្គាប់បញ្ជាលើគោលនយោបាយជាតិ និងអន្តរជាតិរបស់កម្ពុជាបានឡើយ និងមិនបម្រើដាច់ខាត់នូវផលប្រយោជន៍បរទេស»។

សូមសម្តេចប្រធានរដ្ឋសភា មេត្តាយោគយល់ និងទទួលយកនូវហេតុផលនៃឧត្តមគតិរបស់ខ្ញុំចំពោះការគោរពរដ្ឋធម្មនុញ្ញក្នុងគោលដៅពង្រឹងនីតិរដ្ឋនៅកម្ពុជា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសម្តេចប្រធានមេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ និងសូមមេត្តាបញ្ជូនចម្លើយនេះ ទៅម្ចាស់លិខិតចោទប្រកាន់ និងឯកឧត្តម លោកជំទាវ ជាសមាជិក សមាជិការដ្ឋសភាទាំងអស់ តាមការគួរ ។

សូមសម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ តុលា ឆ្នាំ ២០១០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
"ដើម្បីជូនជ្រាប"
-ឯកសារ -កាលប្បវត្តិ